**Declassified to Public**
**12 June 2020**

លេខ៖ D188/1/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 07 / 09 / 2016
ម៉ោង (Time/Heure): 14 : 35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ២០១៦**

ភាសា ៖ **ខ្មែរ/អង់គ្លេស [អង់គ្លេស ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

# ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២ របស់ អោ អាន

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មូស្សេនី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ូវ៉ន
ទី ស្រីនណា
វ៉េន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ មេធាវីការពារក្ដីអោ អាន("មេធាវីការពារក្ដី")បានដាក់*សំណើលើកទីពីររបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន៥៥(១០)*[1]។

៣. នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានបដិសេធសំណើនេះ ដោយកត់សម្គាល់ថា អោ អាន មិនទាន់ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ ហេតុនេះមិនមានសិទ្ធិដាក់សំណើសុំបំពេញកិច្ចស៊ើបសួរឡើយ[2]។

៤. នៅថ្ងៃទី២៧ ខែ មីនា ឆ្នាំ ២០១៥ អតីតសហចៅក្រមកាន់តំណែងខ្ញុំ បានជូនដំណឹង អោ អាន អំពីដីកាសម្រេចដាក់គាត់ឱ្យស្ថិតក្រោមការពិនិត្យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខទួលបេង ទីតាំងសម្លាប់មនុស្សគោកព្រីង និងមន្ទីរសន្តិសុខវត្តអូរត្រកួន[3]។

៥. នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ មេធាវីការពារក្ដី បានដាក់*សេចក្ដីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២* ("សំណើ")[4]។

៦. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ខ្ញុំបានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទប្រព្រឹត្តឧក្រិដ្ឋកម្មថែមទៀតនៅការដ្ឋានពលកម្មដោយបង្ខំអន្លង់ជ្រៃ មន្ទីរសន្តិសុខមិត្តសុប (គរ) វត្តអង្គញជី មន្ទីរសន្តិសុខវត្តបាធាយ មន្ទីរសន្តិសុខវត្តភ្នំប្រុស វត្តតាមះ មន្ទីរសន្តិសុខចម្ការស្វាយ

---

[1]សំណុំរឿង004 ឯកសារ D188 *សំណើលើកទីពីររបស់ តា អាន សុំបំពេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន ៥៥(១០)* ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១៦។

[2]សំណុំរឿង004 ឯកសារ D190 *ដីកាសម្រេចលើសំណើរបស់ តា អា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៤។

[3]សំណុំរឿង004 ឯកសារ D242 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន* ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥។

[4]សំណុំរឿង004 ឯកសារ D188/1 *សេចក្ដីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២* ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥ ("សំណើ")។

ចន្ទី មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក និងមន្ទីរសន្តិសុខវត្តស្រង៉ែ។ ខ្ញុំក៏បានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ និងពីបទអំពើប្រល័យពូជសាសន៍មកលើជនជាតិចាមនៅខេត្តកំពង់ចាម។ ខ្ញុំបានដាក់ អោ អាន ឲ្យស្ថិតក្រោមការពិនិត្យដោយសារតំណែងពីមុនគាត់ជាអនុលេខាភូមិភាគកណ្តាល (ឧត្តរចាស់) ជាសមាជិកនៃគណៈភូមិភាគកណ្តាល(ឧត្តរចាស់) និងជាលេខាតំបន់ ៤១ នៅភូមិភាគកណ្តាល(ឧត្តរចាស់)[5]។

## II. សារណា

៧. ផ្នែកទី ១ នៃសំណើ គឺពាក់ព័ន្ធនឹងវិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីកំណត់ស្ថិតិទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់អង្គហេតុចំនួន ៨ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣("ដីកាសន្និដ្ឋានទី ៣") និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម("ដីកាសន្និដ្ឋានបន្ថែម")[6]។ មេធាវីការពារក្តី ស្នើថា ខ្ញុំគួរតែស៊ើបអង្កេតលើវិធីសាស្ត្រដែលសហព្រះរាជអាជ្ញាអន្តរជាតិ("ស.ព.អ")បានប្រើប្រាស់ ដើម្បី៖

ក) កំណត់ និងអះអាងថា "លំនាំយ៉ាងច្បាស់បានកើតមាននៅក្នុងភូមិភាគកណ្តាលក្រោយការមកដល់របស់ តា អាន និងកម្មាភិបាលភូមិភាគនិរតី ការតម្រូវឲ្យធ្វើការច្រើន ផ្តល់អាហារតិចតួច និងប្រជាជនចំនួនដ៏ច្រើនត្រូវបានចាប់ខ្លួន"។

ខ) កំណត់អត្តសញ្ញាណ"ជនជាតិភាគតិច"។

គ) ប៉ាន់ប្រមាណថា ប្រជាជនចំនួន ៣២ ៦៩០ នាក់ ត្រូវបានសម្លាប់នៅវត្តអូរត្រកួន។

ឃ) ប៉ាន់ប្រមាណថា ប្រជាជនចំនួន ៤០០ ០០០ នាក់បានស្លាប់នៅភូមិភាគកណ្តាល។

ង) ប៉ាន់ប្រមាណថា ប្រជាជនចំនួន ១០ ០០០នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តភ្នំប្រុស វត្តអង្គញ្ញដី ឬភូមិទួលបេង។

---

[5]សំណុំរឿង០០៤ ឯកសារ D303 *កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀតរបស់ អោ អាន* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦។

[6]សំណើ កថាខណ្ឌ ២០។

01325552



ច) ប៉ាន់ប្រមាណថា ប្រជាជនចំនួន ១ ០០០ នាក់ត្រូវបានសម្លាប់នៅគោកព្រីង។

ឆ) ប៉ាន់ប្រមាណថា ជនជាតិចាមប្រមាណ ១០ ០០០ នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួន និង

ជ) សម្រេចថា នៅក្នុងខេត្តកំពង់ចាម "ចំនួនភាគរយខ្ពស់យ៉ាងច្រើន"នៃជនជាតិភាគតិចត្រូវបានសម្លាប់[7]។

៨. ទី២ មេធាវីការពារក្តី ស្នើថា ខ្ញុំគួរតែវាយតម្លៃភាពអាចជឿទុកចិត្តបាននៃវិធីសាស្ត្រទាំងនេះ[8]។ ជាពិសេស ស្នើថា ខ្ញុំគួរតែពិចារណាលើភាពមិនត្រឹមត្រូវ និងទិដ្ឋភាពផ្សេងនៃអង្គហេតុដែលជំទាស់ទៅនឹងតួលេខ និងការកំណត់របស់ ស.ព.អ[9]។

៩. មេធាវីការពារក្តី អះអាងថា ការបំពេញកិច្ចស៊ើបសួរខាងលើទំនងជានាំឱ្យរកឃើញតម្លៃភស្តុតាងដោះបន្ទុក ដោយពិនិត្យឃើញថា វិធីសាស្ត្រទាំងនោះដែលបានអនុវត្តនៅក្នុងសំណុំរឿង ០០២ ត្រូវបានរិះគន់ និងចោទសួរ ហើយទំនងជាថា វិធីសាស្ត្រដូចគ្នានេះ ឬស្រដៀងគ្នានេះអាចនាំឱ្យមានកំហុសឆ្គងនៅក្នុងសំណុំរឿង ០០៤[10]។ ជាងនេះទៀត មេធាវីការពារក្តី អះអាងថា ការស្រាវជ្រាវរបស់ខ្លួនឯង បង្ហាញថា ការប៉ាន់ស្មាន់ទាំងនោះគឺមិនត្រឹមត្រូវ ឬក៏ផ្អែកលើវិធីសាស្ត្រដែលមានកំហុសឆ្គង[11]។

១០. មេធាវីការពារក្តី អះអាងថា ការយល់ដឹងអំពីវិធីសាស្ត្រទាំងនេះគឺមានសារៈសំខាន់ណាស់ដើម្បីការពារក្តី អោ អាន ពីព្រោះថា វិធីសាស្ត្រនេះគឺជាមូលដ្ឋាននៃការចោទប្រកាន់មកលើគាត់[12] ហើយការយល់ដឹងអំពីកំហុសឆ្គងណាមួយគឺមានសារៈសំខាន់ណាស់ដើម្បីប្តឹងតវ៉ាប្រឆាំងនឹងការចោទប្រកាន់អង្គហេតុនៅពេលជំនុំជម្រះក្តី[13]។ ទោះបីជា ព័ត៌មានខ្លះពាក់ព័ន្ធនឹង

---

[7]សំណើ កថាខណ្ឌ ២០។

[8]សំណើ កថាខណ្ឌ ២។

[9]សំណើ កថាខណ្ឌ ២១។

[10]សំណើ កថាខណ្ឌ ២៤។

[11]សំណើ កថាខណ្ឌ ៨។

[12]សំណើ កថាខណ្ឌ ២៣។

[13]សំណើ កថាខណ្ឌ ២៤។

01325553



វិធីសាស្ត្រនេះមានរួចហើយក៏ដោយ ក៏មេធាវីការពារក្តី លើកឡើងថា ខ្លួនមិនបានរកឃើញថាមានឯកសារគ្រប់គ្រាន់អំពីវិធីសាស្ត្រទាក់ទងនឹងសំណុំរឿង ០០៤ ឡើយ[14]។

១១. ទី ៣ មេធាវីការពារក្តី ស្នើថា ខ្ញុំគួរតែស៊ើបអង្កេត និងកំណត់អំពីកាលបរិច្ឆេទ និងមូលហេតុនៃការស្លាប់របស់ជនដែលត្រូវបានអះអាងថាជាជនរងគ្រោះ[15] ដែល មេធាវីការពារក្តី អះអាងថាគឺជា“*ចំណុចស្នូលនៃពិរុទ្ធភាពនៅក្នុងរឿងក្តីព្រហ្មទណ្ឌ*”[16]។

១២. ទី ៤ មេធាវីការពារក្តី ផ្តល់អនុសាសន៍ថា ខ្ញុំគួរតែតែងតាំងអ្នកជំនាញកោសលវិច័យម្នាក់ក្នុងករណីចាំបាច់[17]។ មេធាវីការពារក្តី ទទួលស្គាល់ថា ស.ច.ស ធ្លាប់បានតែងតាំងអ្នកជំនាញឱ្យវិភាគវិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីគណនាចំនួនជនរងគ្រោះសរុបពីរបបខ្មែរក្រហម[18] ប៉ុន្តែ មេធាវីការពារក្តី អះអាងថា មិនមានការវិភាគជាក់លាក់បានធ្វើឡើងឡើយទាក់ទងនឹងស្ថិតិទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០៤[19]។

## III. ពិភាក្សា

១៣. អង្គបុរេជំនុំជម្រះធ្លាប់បានបញ្ជាក់ថា ភាគីដែលស្នើសុំបំពេញកិច្ចស៊ើបសួរ“ត្រូវបំពេញលក្ខខណ្ឌត្រួតលើគ្នាចំនួនពីរ [...] ពោលគឺ សំណើសុំត្រូវតែ៖

> *(១) កំណត់បង្ហាញអំពីសកម្មភាពដែលត្រូវធ្វើ ឬដីកាដែលត្រូវធ្វើ ដោយមានការបញ្ជាក់ឱ្យបានច្បាស់លាស់(“លក្ខខណ្ឌនៃភាពច្បាស់លាស់”) និង(២) បង្ហាញឱ្យបានពិស្តារអំពីមូលហេតុអ្វីបានជាសំណើបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ ឬកិច្ចដែលកើតចេញមកពីដីកាដែលធ្វើឡើង អនុលោមតាមវិធាន*

---

[14]សំណើ កថាខណ្ឌ ១១។

[15]សំណើ កថាខណ្ឌ ២១។

[16]សំណើ កថាខណ្ឌ ៤។

[17]សំណើ កថាខណ្ឌ ៣ និង ២២។

[18]សំណុំរឿង០០២ ឯកសារ D140 *ដីកាចាត់តាំងអ្នកជំនាញប្រជាសាស្ត្រ* ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩។

[19]សំណើ កថាខណ្ឌ ៩។

*៥៥(១០)នៃវិធានផ្ទៃក្នុង មានការ"ពាក់ព័ន្ធទៅនឹងការបញ្ជាក់នូវការពិត"ជាបឋម(លក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម)"*[20]។

១៤. លក្ខខណ្ឌនៃភាពច្បាស់លាស់ តម្រូវឱ្យភាគីដែលស្នើ ជាប់កាតព្វកិច្ច"*ត្រូវមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីធ្វើការបង្ហាញឱ្យបានច្បាស់លាស់ដល់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងកិច្ចការអ្វីដែលសហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរ*"[21]។ ហេតុនេះ ខ្ញុំមិនជាប់លក្ខខណ្ឌត្រូវអនុញ្ញាតតាមសំណើមានលក្ខណៈជាទូទៅ ឬប៉ាន់ស្មាន ដែលស្នើសុំស្វែងរកភស្តុតាងដោះបន្ទុកឡើយ[22]។ ប៉ុន្តែ ភាគីដែលស្នើ ត្រូវតែចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីវត្តមាននៃភស្តុតាងដែលត្រូវស្វែងរក[23]។ ឧទាហរណ៍ អ.ប.ជ បានសម្រេចថា សំណើសុំដែលមិនបានលើកឡើងច្បាស់លាស់អំពីចំនួនឯកសារ ឬអំពីទីតាំងច្បាស់លាស់ដែលប្រមូលបានឯកសារនោះ ឬទីតាំងទុកដាក់ឯកសារនោះ គឺខកខានមិនបានបំពេញលក្ខខណ្ឌនៃភាពច្បាស់លាស់ឡើយ[24]។

១៥. លក្ខខណ្ឌនៃភាពពាក់ព័ន្ធ មានលក្ខខណ្ឌរងចំនួនពីរ។ ទី ១ សំណើ ត្រូវ"*មានការពាក់ព័ន្ធជាមួយនឹងវិសាលភាពនៃការស៊ើបសួរ អនុលោមតាមការកំណត់ និងព្រំដែនដែលបានកំណត់*

---

[20]សំណុំរឿង ០០២ ឯកសារ D365/2/17 *សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង* ("សាលដីកាស្តីពីការពិចារណាឡើងវិញ") ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៤៧។

[21]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

[22]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨ និង ៥១។

[23]សំណុំរឿង០០២ ឯកសារ D100/9/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៣១។ សំណុំរឿង០០២ ឯកសារD164/4/13*សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៣៩។ សំណុំរឿង០០២ ឯកសារ D273/3/5 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់ ក.ស.ច.ស លើសំណើលើកទី ១៨ របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ១៩-២០, ២៦ និង ២៩។

[24]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៨។

*ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម*"[25]។ ទី ២ សំណើ "*ត្រូវរៀបរាប់លម្អិតអំពីមូលហេតុអ្វីបានជាកិច្ចស្នើដែលជាកម្មវត្ថុនៃដីកាសម្រេច នឹងនាំឱ្យរកឃើញនូវការពិត*"[26]។ លក្ខខណ្ឌនេះតម្រូវថា ភាគីដែលស្នើសុំ ត្រូវបញ្ជាក់ពីចំណង ទាក់ទងជាបឋមរវាងកិច្ចស៊ើបសួរដែលបានស្នើសុំ ជាមួយនឹងបញ្ហាដែលស្ថិតនៅក្នុងវិសាល ភាពនៃកិច្ចស៊ើបសួរ[27]។ ក្នុងករណីដែលសំណើពាក់ព័ន្ធនឹងភស្តុតាងដោះបន្ទុក ភាគីដែលស្នើសុំ ត្រូវបង្ហាញពីមូលហេតុជាបឋមដែលថា ការបំពេញកិច្ចស៊ើបសួរអាចនាំឱ្យមានភស្តុតាងដោះ បន្ទុក[28]។

## ក. ការស៊ើបអង្កេតអំពីវិធីសាស្ត្រដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

១៦. ការចោទប្រកាន់ជាច្រើនក្នុងចំណោមការចោទប្រកាន់អំពីអង្គហេតុដែលជាកម្មវត្ថុនៃសំណើ គឺមានការគាំទ្រដោយយោងលើរបាយការណ៍នានា ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯក សារកម្ពុជា។ ជាដំបូង វាជាការងាយត្រូវដោះស្រាយបញ្ហាចោទប្រកាន់ទាំងនោះសិន។

១៧. ចាប់តាំងពីមេធាវីការពារក្តីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរនេះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ ស៊ិន ឃិន និង ហាក់ សុផល ដែលអ្នកទាំងពីរនេះធ្លាប់ធ្វើការឱ្យ មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយបានចូលរួមរៀបចំរបាយការណ៍ទាំងនោះដែលបានដក ស្រង់នៅក្នុងដីកាសន្និដ្ឋានទី ៣[29]។ ការស្តាប់ចម្លើយមួយទៀតរបស់ ក.ស.ច.ស ជាមួយនឹង

---

[25]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៤៩។

[26]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០។

[27]សាលដីកាស្តីពីការពិចារណាឡើងវិញ កថាខណ្ឌ ៥០-៥១។

[28]សំណុំរឿង002 ឯកសារ D353/2/3 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ"ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០១០* ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ កថាខណ្ឌ ៤៧។

[29]សំណុំរឿង004 ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥។ សំណុំរឿង004 ឯកសារ D219/363 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាក់ សុផល* ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៥។

ផេង ពង្សរ៉ាស៊ី បានធ្វើឡើងនៅដើមឆ្នាំនោះ[30]។ សាក្សីនីមួយៗក្នុងចំណោមសាក្សីទាំងនេះបានផ្តល់ភស្តុតាងអំពីវិធីសាស្ត្រជាទូទៅដើម្បីកំណត់ចំនួនជនរងគ្រោះនៅក្នុងរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា[31]។ កំណត់ហេតុនៃការស្តាប់ចម្លើយទាំងបី("កំណត់ហេតុស្តាប់ចម្លើយ")បានដាក់ចូលក្នុងសំណុំរឿង ០០៤ រួចហើយ។

១៨. បន្ថែមពីលើនេះទៀត របាយការណ៍មួយពីអ្នកជំនាញប្រជាសាស្ត្រឈ្មោះ Ewa Tabeau ដែលធ្វើការវាយតម្លៃវិធីសាស្ត្រប្រើប្រាស់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា បានដាក់ចូលក្នុងសំណុំរឿង ០០៤ រួចហើយ[32]។ ទោះបីជារបាយការណ៍នេះមិនផ្តោតឱ្យបានច្បាស់លាស់អំពីភូមិភាគកណ្តាល ក៏ដោយ ក៏របាយការណ៍នេះបានត្រួតពិនិត្យដំណើរការនីតិវិធីដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់នៅក្នុងគម្រោងរៀបចំផែនទីទីតាំងរណ្តៅសាកសពរួម[33]។ Tabeau ចាត់ទុកថា ដំណើរការនីតិវិធីទាំងនោះគឺ *"មានភាពគ្រប់គ្រាន់អាចចាត់ទុកថា ការប៉ាន់ប្រមាណរបស់ពួកគេមានលក្ខណៈហ្មត់ចត់ បើទោះបីជាវាគ្រាន់តែជាការប៉ាន់ស្មានក្តី"*[34]។ របាយការណ៍នេះបានពិចារណាបញ្ហានានាទាក់ទងនឹងការស្លាប់ដោយសារមូលហេតុធម្មជាតិ និងកត្តានានាដែលមិនទាក់ទងនឹងការចោទប្រកាន់អំពីអំពើឧក្រិដ្ឋកម្មរបស់ អោ អាន[35]។

១៩. របាយការណ៍វិភាគមួយទៀតនៅក្នុងសំណុំរឿង ០០២ រៀបចំឡើងដោយ Graig Etcheson ចំណងជើង *"ចំនួនដែលបញ្ជាក់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅកម្ពុជា"* ("របាយការណ៍របស់ Graig Etcheson") គឺធ្វើការសង្ខេបជាទូទៅអំពីវិធីសាស្ត្រ និងភាពមិនត្រឹមត្រូវជាសក្តានុពលនៃដំណើរការនីតិវិធីដែលរៀបចំផែនទីទីតាំងរណ្តៅសាកសពរបស់មជ្ឈមណ្ឌល

---

[30]សំណុំរឿង០០៤ ឯកសារ D219/144 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផេង ពង្សរ៉ាស៊ី* ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥។

[31]សំណុំរឿង០០៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ុន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ចម្លើយ ១៧។

[32]សំណុំរឿង ០០២ ឯកសារ D6.1.197 *ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ("របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ")* ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៩។

[33]របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ ទំព័រ ២៣-៣៤ (ERN 00499440-00499451)។

[34]របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ ទំព័រ ២៥ (ERN 00499442)។

[35]របាយការណ៍អ្នកជំនាញផ្នែកប្រជាសាស្ត្រ ទំព័រ ២៥ (ERN 00499442)។

ឯកសារកម្ពុជា ហើយពិភាក្សាអំពីបញ្ហារាប់ចំនួនទ្វេដង ការស្លាប់ដោយសារមូលហេតុធម្មជាតិ ជំងឺ ឬអត់អាហារ និងកត្តានានាដែលមិនទាក់ទងនឹងអំពើឧក្រិដ្ឋដែលបានចោទ[36]។ របាយការណ៍នេះកត់សម្គាល់ថា ការសិក្សាដែលអាជ្ញាធរបានធ្វើឡើងនៅទសវត្សរ៍ឆ្នាំ ១៩៨0 គឺមានចន្លោះប្រហោងយ៉ាងខ្លាំងដែលមានហានិភ័យខ្ពស់អាចរាប់ចំនួនទ្វេដង[37] ប៉ុន្តែ ចំណុចនេះត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលស្គាល់ ហើយត្រូវបានយកមកពិចារណានៅពេលដែលរៀបចំរបាយការណ៍របស់ខ្លួន[38]។ ខ្ញុំនឹងដាក់របាយការណ៍នេះចូលក្នុងសំណុំរឿង។

២០. ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវស៊ើបអង្កេតថែមទៀតលើវិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់នៅក្នុងរបាយការណ៍នានាដែល ស.ព.អ បានដកស្រង់ឡើយ (“វិធីសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា”)។ វិធីសាស្ត្រនេះត្រូវបានពិភាក្សាយ៉ាងលម្អិតនៅក្នុងឯកសារខាងលើ។ ដូចដែលកំណត់ហេតុស្តាប់ចម្លើយ ហាក់ សុផល និង ស៊ិន ឃិន បានបង្ហាញ វិធីសាស្ត្ររបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគកណ្តាល គឺដូចគ្នាជាមួយនឹងវិធីសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍នានាដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានទី ៣។

**ខ. ការស៊ើបអង្កេតវិធីសាស្ត្រទាក់ទងនឹងការចោទប្រកាន់ ក) ដល់ ជ)**

*ក) លំនាំយ៉ាងច្បាស់បានកើតមាននៅក្នុងភូមិភាគកណ្តាលក្រោយការមកដល់របស់ តា អាន និងកម្មាភិបាលភូមិភាគនិរតី ការតម្រូវឱ្យធ្វើការច្រើន ផ្តល់អាហារតិចតួច និងប្រជាជនចំនួនដ៏ច្រើនត្រូវបានចាប់ខ្លួន*

២១. ការចោទប្រកាន់នេះឃើញមាននៅកថាខណ្ឌ ២២ នៃដីកាសន្និដ្ឋានទី ៣។ ដើម្បីគាំទ្រការចោទប្រកាន់នេះ ស.ព.អ បានដកស្រង់ចម្លើយសាក្សីដែលទទួលបានដោយអ្នកស៊ើបអង្កេតមកពីការិយាល័យសហព្រះរាជអាជ្ញា (“ក.ស.ព”)[39] របាយការណ៍រៀបចំផែនទីទីតាំងចំនួន៤

[36]សំណុំរឿង00២ ឯកសារ E3/1807 *ចំនួនដែលបញ្ជាក់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅកម្ពុជា* ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១២ (“របាយការណ៍របស់ Graig Etcheson”)។

[37]របាយការណ៍របស់ Graig Etcheson ទំព័រ ៧[អង់គ្លេស]។

[38]របាយការណ៍របស់ Graig Etcheson ទំព័រ ៨[អង់គ្លេស]។

[39]សំណុំរឿង00៤ ឯកសារ D1.3.11.42 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ័ន្ត ពៅ* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២00៨។ សំណុំរឿង00៤ ឯកសារ D1.3.11.5 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ យ៉ា* ថ្ងៃទី ០១ ខែ សីហា

របស់មជ្ឈមណ្ឌលឯកសារកម្ពុជា[40] របាយការណ៍មួយរបស់ ស.ព.អ ចំណងជើង"*បេសកកម្មរបស់ការិយាល័យសហព្រះរាជអាជ្ញាចុះទៅស្រុកបាធាយ ខេត្តកំពង់ចាម*"("របាយការណ៍ស្ដីពីការចុះបេសកកម្មរបស់ ក.ស.ព")[41] និងរបាយការណ៍របស់ Henri Locard ចំណងជើង *កំពង់ចាម៖ ច្រាំងទន្លេមេគង្គខាងលិច តំបន់ឧត្តរចាស់ ភូមិភាគ ឬតំបន់ ៤១ និង ៤២* ("របាយការណ៍របស់ Henri Locard")[42]។

២២. សាក្សី ៩ នាក់ក្នុងចំណោមសាក្សីដែល ស.ព.អ បានដកស្រង់ គឺត្រូវបានអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស")ស្ដាប់ចម្លើយ ហើយចម្លើយដើមរបស់

---

ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.9 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាន ហ៊ាង* ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.35 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នីវ ស៊ុន* ថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.22 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឃុន សារ៉េត* ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.44 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រស់ ឈាង ហៅ អាចារ្យ ឈាង* ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.7 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចេង គុល និងគុណ សុខា* ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.47 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង ស្រ៊ុន* ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.11 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជិន ស៊ីណាល់* ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.45 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សាន សុន* ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.4 *កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី បាវ ទ្រព្យ* ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារ D1.3.11.38 *កំណត់ហេតុនៃការស្ដាប់ចម្លើយរបស់ ក.ស.ព ជាមួយ ប៉ាវ លី* ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

[40]សំណុំរឿង០០៤ ឯកសារD1.3.10.9 *មជ្ឈមណ្ឌលឯកសារកម្ពុជា ការកំណត់ផែនទីវាលពិឃាតរបស់កម្ពុជា ឆ្នាំ១៩៩៧៖ ខេត្តកំពង់ធំ*។ សំណុំរឿង០០៤ ឯកសារ D1.3.10.12 *មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងការងារកំណត់ទីតាំងលើផែនទី* ចំណងជើង *"ខេត្តកំពង់ចាម"* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ សំណុំរឿង០០៤ ឯកសារD1.3.10.16 *មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងការងារកំណត់ទីតាំងលើផែនទី ឆ្នាំ ១៩៩៩ ៖ ខេត្តកំពង់ធំ* ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៩។ សំណុំរឿង០០៤ ឯកសារD1.3.10.18 *មជ្ឈមណ្ឌលឯកសារកម្ពុជា របាយការណ៍នៃការចុះស្រាវជ្រាវទីតាំងប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម ឆ្នាំ ២០០០* ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០០។

[41]សំណុំរឿង០០៤ ឯកសារD1.3.10.22 *បេសកកម្មរបស់ការិយាល័យសហព្រះរាជអាជ្ញាចុះទៅស្រុកបាធាយ ខេត្តកំពង់ចាម* ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ ("របាយការណ៍ស្ដីពីការចុះបេសកកម្មរបស់ ក.ស.ព")។

[42]សំណុំរឿង០០៤ ឯកសារ D1.3.11.16 *ឧបសម្ព័ន្ធ ខ ០០១០៖ Henri LOCARD "របាយការណ៍៖ កំពង់ចាម៖ ច្រាំងទន្លេមេគង្គខាងលិច តំបន់ឧត្តរចាស់ ភូមិភាគ ឬតំបន់ ៤១ និង ៤២" ឆ្នាំ ២០០៧* ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៧។

01325559



ពួកគាត់ត្រូវបានបញ្ឈាក់[43]។ ចាប់តាំងពីនោះមក សាក្សី ៣ នាក់ក្នុងចំណោមសាក្សីទាំងនេះរបស់ ក.ស.ព បានស្លាប់ ហើយមិនអាចស្តាប់ចម្លើយបានឡើយ[44]។ នៅក្នុងចម្លើយដែលបានផ្តល់ឲ្យ ក.ស.ព សាក្សីទាំងនេះ រៀបរាប់អំពីស្ថានភាពកាន់តែលំបាកបន្ទាប់ពីកម្មាភិបាលភូមិភាគនិរតី ចូលមកដល់។ ប៉ាវ លី គឺជាសាក្សីតែម្នាក់គត់ក្នុងចំណោមសាក្សី ១៣ នាក់ដែលមិនបានស្តាប់ចម្លើយ ពីព្រោះថា ខ្ញុំយល់ឃើញថា ការស៊ើបអង្កេតលើមន្ទីរសន្តិសុខមិត្តសុប បានបញ្ចប់សព្វគ្រប់ហើយ។ មន្ទីរសន្តិសុខមិត្តសុប ត្រូវបានស៊ើបអង្កេតយ៉ាងច្រើន។ ដោយផ្អែកលើចម្លើយរបស់ ប៉ាវ លី ដែលបានប្រាប់ទៅ ក.ស.ព ដោយរៀបរាប់អំពីការសម្លាប់កើនឡើង និងការអត់អាហារនោះ ទើប ខ្ញុំមិនជឿជាក់ថា ការស្តាប់ចម្លើយសាក្សីរូបនេះនឹងទំនងជាមានលទ្ធផលភស្តុតាងដោះបន្ទុកឡើយ។

២៣. របាយការណ៍ស្តីពីបេសកកម្មរបស់ ក.ស.ព ដែលបានបង្ហាញខាងលើ គឺយោងលើព័ត៌មានទទួលបានពីសាក្សីឈ្មោះ អ៊ុំ រស់[45]។ ភស្តុតាងរបស់គាត់គឺថា ការសម្លាប់មនុស្សបានកើនឡើងនៅពេលដែលកម្មាភិបាលនិរតីចូលមកដល់នៅឆ្នាំ ១៩៧៧[46]។ អ៊ុំ រស់ ត្រូវបានអ្នកស៊ើបអង្កេត

[43]សំណុំរឿង០០៤ ឯកសារ D74 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ័ន្ត ពៅ* ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១។ សំណុំរឿង០០៤ ឯកសារD87 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៉ាង* ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១។ សំណុំរឿង០០៤ ឯកសារ D3/10 *នីវ ស៊ុន* ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១០។ សំណុំរឿង០០៤ ឯកសារ D93 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន សារ៉េត* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១១។ សំណុំរឿង០០៤ ឯកសារ D219/327 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង តុល* ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥។ សំណុំរឿង០០៤ ឯកសារ D76 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស្រ៊ុន* ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១។ សំណុំរឿង០០៤ ឯកសារ D78 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជិន ស៊ីណាល់* ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១។ សំណុំ រឿង ០០៤ ឯកសារ D107/2 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ សុន* ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២។ សំណុំរឿង០០៤ ឯកសារ D3/5 *បាវ ទ្រព្យ* ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០។

[44] ចាន់ យ៉ា(រង់ចាំលិខិតមរណភាព)។ រស់ ឈាង សំណុំរឿង០០៤ ឯកសារ D100 *របាយការណ៍ស្តីពីការចុះស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤ ចាប់ពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១១* ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។ គន់ សុត្ថា សំណុំរឿង០០៤ ឯកសារ D100.1 *លិខិតបញ្ជាក់មរណភាព គន់ សុត្ថា* ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។

[45]សំណុំរឿង០០៤ ឯកសារD1.3.10.22 *បេសកកម្មរបស់ការិយាល័យសហព្រះរាជអាជ្ញាចុះទៅស្រុកបាធាយ ខេត្តកំពង់ចាម* ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៧ ទំព័រ ១៣។

[46]របាយការណ៍ស្តីពីការចុះបេសកកម្មរបស់ ក.ស.ព កថាខណ្ឌ ៣៣។

របស់ ក.ស.ច.ស ស្តាប់ចម្លើយនៅឆ្នាំ ២០១០ ហើយគាត់បានបញ្ជាក់ពីភាពត្រឹមត្រូវនៃចម្លើយដើមរបស់គាត់ដែលផ្តល់ឱ្យ ក.ស.ព[47]។

២៤. របាយការណ៍របស់ Henri Locard យោងលើភស្តុតាងរបស់ "សូ ស៊ីន្នន"[48]។ សាក្សីនេះមិនត្រូវបានអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ស្តាប់ចម្លើយឡើយ ពីព្រោះថា ភស្តុតាងដែលសូ ស៊ីន្នន បានផ្តល់ឱ្យគឺពាក់ព័ន្ធតែជាមួយនឹងការសម្លាប់មនុស្សកើនឡើងនៅឆ្នាំ ១៩៧៧ នៅវត្តព្រៃកកក់តែប៉ុណ្ណោះ ដែលស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរសំណុំរឿង ០០៤។

*ខ) កំណត់អត្តសញ្ញាណ "ជនជាតិភាគតិច"*

២៥. ការលើកឡើងអំពី *ជនជាតិភាគតិច* ឃើញមាននៅកថាខណ្ឌ ៤៨ នៃដីកាសន្និដ្ឋានទី ៣។ ស.ព.អ ចោទថា *"ក្នុងចំណោមប្រជាជនជាង ១៥៨ ០០០ នាក់ដែលជឿថាត្រូវបានសម្លាប់នៅក្នុងខេត្តកំពង់ចាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានប្រហែលជា ៧៤ ០០០ នាក់ក្នុងចំណោមប្រជាជនទាំងនោះ (ស្មើរតែ ៥០ ភាគរយនៃចំនួនស្លាប់សរុប) ត្រូវបានស្គាល់ថាជា "ជនជាតិភាគតិច""*។ ដើម្បីគាំទ្រការចោទប្រកាន់នេះ ស.ព.អ បានដកស្រង់របាយការណ៍រៀបចំផែនទីទីតាំងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចំណងជើង *មជ្ឈមណ្ឌលឯកសារកម្ពុជា ការបញ្ជាក់ពីទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជា ឆ្នាំ ១៩៩៧ ក្នុងខេត្តកំពង់ចាម* ("របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីពីកំពង់ចាមឆ្នាំ ១៩៩៧")[49]។

២៦. តាមសំអាងហេតុដែលបានបង្ហាញនៅកថាខណ្ឌ ១៦ ដល់ ២០ ខាងលើ ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវស៊ើបអង្កេតថែមទៀតលើវិធីសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឡើយ។

*គ) ប៉ាន់ប្រមាណថា ប្រជាជនចំនួន ៣២ ៦៩០ នាក់ ត្រូវបានសម្លាប់នៅវត្តអូរត្រកួន*

---

[47]សំណុំរឿង០០៤ ឯកសារ D3/7 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ រស់* ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១០។

[48]របាយការណ៍របស់ Henri Locard ទំព័រ ១៨[អង់គ្លេស]។

[49]សំណុំរឿង០០៤ ឯកសារ D1.3.10.8 *មជ្ឈមណ្ឌលឯកសារកម្ពុជា ការបញ្ជាក់ពីទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជា ឆ្នាំ ១៩៩៧ ក្នុងខេត្តកំពង់ចាម* ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១០។

២៧. ការចោទប្រកាន់នេះឃើញមាននៅកថាខណ្ឌ ២៣ នៃដីកាសន្និដ្ឋានទី ៣។ តួលេខចំនួន ៣២ ៦៩០ គឺយកពីរបាយការណ៍មួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចំណងជើង *របាយការណ៍ស្តីអំពីដំណើរទស្សនៈកិច្ចរបស់ក្រុមគួសផែនទីគម្រោងស្តីពីអំពើប្រល័យពូជសាសន៍កម្ពុជាទៅកាន់ខេត្តកំពង់ចាម* ("របាយការណ៍របស់គម្រោងស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាស្តីពីកំពង់ចាម ឆ្នាំ ១៩៩៥")[50]។

២៨. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់ចម្លើយ សេង ស៊្រុន សាឡើងវិញនៅក្នុងសំណុំរឿង ០០២ ហើយកំណត់ហេតុស្តាប់ចម្លើយនេះបានដាក់ចូលក្នុងសំណុំរឿង ០០៤[51]។ គាត់បានបញ្ជាក់ថា តួលេខនេះគឺយកពីបញ្ជីឈ្មោះអ្នកទោស ប៉ុន្តែ គាត់មិនដឹងថាបញ្ជីឈ្មោះនេះនៅកន្លែងណាទេបច្ចុប្បន្ននេះ[52]។ គាត់បានលើកឡើងថា ឈុន ហ៊ុន ឬ ម៉ៅ ពិរុណ អាចដឹង[53]។ ឈុន ហ៊ុន មិនអាចស្តាប់ចម្លើយបានឡើយ ពីព្រោះថាគាត់ស្លាប់ហើយ[54]។ ម៉ៅ ពិរុណ បច្ចុប្បន្ននេះគឺជាអភិបាលរងខេត្តកណ្តាល[55]។ ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវស្តាប់ចម្លើយគាត់ឡើយ ទាក់ទងនឹងការប៉ាន់ស្មានចំនួនជនរងគ្រោះ ៣២ ៦៩០ នាក់របស់ ស.ព.អ ដោយពិនិត្យឃើញថា វិធីសាស្ត្រដែលគាំទ្រតួលេខរបស់ ស.ព.អ គឺមានលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ សេង ស៊្រុន។

### *ឃ) ប៉ាន់ប្រមាណថា ប្រជាជនចំនួន ៤០០ ០០០ នាក់បានស្លាប់នៅភូមិភាគកណ្តាល*

---

[50] សំណុំរឿង០០៤ ឯកសារ D1.3.10.5 *របាយការណ៍ស្តីអំពីដំណើរទស្សនៈកិច្ចរបស់ក្រុមគួសផែនទីគម្រោងស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ទៅកាន់ខេត្តកំពង់ចាម* ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥ ទំព័រ ៦។

[51] សំណុំរឿង០០៤ ឯកសារ D6.1.381 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊្រុន* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩។

[52] សំណុំរឿង០០៤ ឯកសារ D6.1.381 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊្រុន* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤។

[53] សំណុំរឿង០០៤ ឯកសារ D6.1.381 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊្រុន* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤។

[54] សំណុំរឿង០០៤ ឯកសារ D219/97 *របាយការណ៍នៃសកម្មភាពនៃការស៊ើបអង្កេត* ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ ទំព័រ ១។

[55] សំណុំរឿង០០៤ ឯកសារ D6.1.381 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊្រុន* ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៤។

២៩. ការអះអាងនេះមានប្រភពមកពីកថាខណ្ឌ ១១ នៃដីកាសន្និដ្ឋានទី ៣។ តួលេខនេះមានលម្អិតនៅជើងទំព័រ ៦ ដែលបញ្ជាក់ថា *"ចំនួនអ្នកស្លាប់សរុបនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនៅក្នុងខេត្តកំពង់ធំ គឺ ៣២៤ ០០០ ហើយចំនួនស្លាប់សរុបនៅក្នុងខេត្តកំពង់ចាម គឺជាង ១៥៨ ០០០"*។ អាចសន្មតបានថា ស.ព.អ បានបូកបញ្ចូលស្ថិតិទាំងពីរនេះដើម្បីកំណត់ថាចំនួនអ្នកស្លាប់សរុបនៅភូមិភាគកណ្តាល គឺ ៤០០ ០០០ នាក់។ ដីកាសន្និដ្ឋានទី ៣ ដកស្រង់របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីពីកំពង់ធំ ឆ្នាំ ១៩៩៧ និងរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីពីកំពង់ចាម ឆ្នាំ ១៩៩៧។

៣០. តាមសំអាងហេតុដែលបានបង្ហាញនៅកថាខណ្ឌ ១៦ ដល់ ២០ ខាងលើ ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវស៊ើបអង្កេតថែមទៀតលើវិធីសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឡើយ។

*ង) ប៉ាន់ប្រមាណថា ប្រជាជនចំនួន ១០ ០០០នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តភ្នំប្រុស វត្តអង្គញដី ឬភូមិទួលបេង*

៣១. ការអះអាងនេះមានប្រភពមកពីកថាខណ្ឌ ៣០ នៃដីកាសន្និដ្ឋានទី ៣ ដែលដកស្រង់របាយការណ៍ពីកម្មវិធីស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ស្តីពីកំពង់ចាម ឆ្នាំ ១៩៩៥ របាយការណ៍មួយពីអ្នកស៊ើបអង្កេតរបស់ ក.ស.ព ចំណងជើង *របាយការណ៍បេសកកម្ម ក.ស.ព ចុះទៅតំបន់ ៤១(ប្រតិបត្តិការនៅលើទឹកដីតាមដងទន្លេ) ("របាយការណ៍បេសកកម្មតាមដងទន្លេរបស់ ក.ស.ព")*[56] របាយការណ៍របស់ Henri Locard និងការស្តាប់ចម្លើយរបស់ ក.ស.ព ជាមួយនឹង ឈ្មោក លីម[57]។

៣២. របាយការណ៍បេសកកម្មតាមដងទន្លេរបស់ ក.ស.ព យោងលើកូនសៀវភៅណែនាំមួយរៀបចំឡើងដោយអាជ្ញាធរខេត្តនៅឆ្នាំ ២០០៧[58]។ ក្រោយមក សៀវភៅនេះ ក.ស.ច.ស ទទួលបាន ហើយបានដាក់ចូលក្នុងសំណុំរឿង ០០៤[59]។

---

[56]សំណុំរឿង០០៤ ឯកសារ D1.3.10.23 *របាយការណ៍បេសកកម្ម ក.ស.ព ចុះទៅតំបន់ ៤១ (ប្រតិបត្តិការនៅលើទឹកដីតាមដងទន្លេ)* ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៨ ("របាយការណ៍បេសកកម្មតាមដងទន្លេរបស់ ក.ស.ព")។

[57]សំណុំរឿង០០៤ ឯកសារ D1.3.11.21 *កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ ឈ្មោក លីម* ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៨។

[58]របាយការណ៍បេសកកម្មតាមដងទន្លេរបស់ ក.ស.ព ទំព័រ ៩-១០។

៣៣. របាយការណ៍របស់ Henri Locard ពឹងផ្អែកលើកិច្ចសម្ភាសន៍ជាមួយនឹង ឡាយ សុខា ដែលបានបញ្ជាក់ថា លលាដ៍ក្បាលចំនួន ៨ ០០០ បានរកឃើញនៅជិតភ្នំប្រុស[60]។ ឡាយ សុខា មិនត្រូវបានអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ស្តាប់ចម្លើយឡើយ ពីព្រោះថា មិនមានការបង្ហាញថា គាត់បានឃើញផ្ទាល់នូវឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មដែលបានចោទឡើយ ហើយមានការលើកឡើងថា គាត់នៅចម្ការលើនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[61]។ ហេតុនេះ ខ្ញុំចាត់ទុកថា តួលេខលលាដ៍ក្បាលចំនួន ៨ ០០០ មិនអាចទុកចិត្តបានទេ ហើយនៅពេលបច្ចុប្បន្ននេះ ខ្ញុំមិនមាននិន្នាការពឹងផ្អែកលើភស្តុតាងនេះនៅក្នុងដីកាដំណោះស្រាយឡើយ។ ហេតុនេះ ខ្ញុំយល់ឃើញថា ការស្តាប់ចម្លើយ ឡាយ សុខា អំពីបញ្ហានេះ មិនចាំបាច់ធ្វើឡើងដើម្បីបញ្ជាក់ពីការពិតឡើយ។

៣៤. ទោះបីជាដីកាសន្និដ្ឋានទី ៣ យោងលើការស្តាប់ចម្លើយរបស់ ក.ស.ព ជាមួយ ឃ្លោក លឹម ដើម្បីគាំទ្រការចោទប្រកាន់នេះក៏ដោយ ក៏ ព័ត៌មាននេះតាមពិតបានមកពីប្រពន្ធរបស់គាត់ឈ្មោះ ធុក នួន[62] ដែលបង្ហាញឱ្យឃើញថាជាអ្នកមានវត្តនៅក្នុងអំឡុងពេលស្តាប់ចម្លើយនេះ។ អ្នកស៊ើបអង្កេតម្នាក់របស់ ក.ស.ច.ស បានស្តាប់ចម្លើយ ឃ្លោក លឹម[63]។ ប៉ុន្តែ ធុក នួន មិនត្រូវបានស្តាប់ចម្លើយឡើយ ពីព្រោះថា គាត់គ្រាន់តែលើកឡើងថាបានឃើញលលាដ៍ក្បាលក្រោយការដួលរលំរបបខ្មែរក្រហមតែប៉ុណ្ណោះ ហើយគាត់បានបញ្ជាក់ថា គាតមិនដឹងថាលលាដ៍ទាំងនោះមានប្រភពដើមពីណានោះទេ។ ហេតុនេះ ការស្តាប់ចម្លើយគាត់ មិនទំនងជាមានលទ្ធផលភស្តុតាងគួរឱ្យទុកចិត្តបានឡើយ ហើយការស្តាប់ចម្លើយគាត់ក៏មិនចាំបាច់ធ្វើឡើងដើម្បីបញ្ជាក់ពីការពិតឡើយ។

---

[59]សំណុំរឿង០០៤ ឯកសារ D219/812.1 *ឯកសារភ្ជាប់ជាមួយ៖ ប្រវត្តិវត្តសុវណ្ណគិរីរតនៈភ្នំប្រុស និងរឿងភ្នំប្រុស ភ្នំស្រី* អត់មានការចុះកាលបរិច្ឆេទ (បានដាក់ចូលក្នុងសំណុំរឿង នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៦)។

[60]របាយការណ៍របស់ Henri Locard ទំព័រ ១។

[61]របាយការណ៍របស់ Henri Locard ទំព័រ ១។

[62]សំណុំរឿង០០៤ ឯកសារ D1.3.11.21 *កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ ឃ្លោក លឹម* ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៨ ទំព័រ ៥។

[63]សំណុំរឿង០០៤ ឯកសារ D80 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃ្លោក លឹម* ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១។

01325564



### ច) *ប៉ាន់ប្រមាណថា ប្រជាជនចំនួន ១ ០០០ នាក់ត្រូវបានសម្លាប់នៅគោកព្រីង*

៣៥. ការអះអាងនេះមានប្រភពមកពីកថាខណ្ឌ ៣២ នៃដីកាសន្និដ្ឋានទី ៣ ដែលយោងលើការស្តាប់ចម្លើយរបស់ ក.ស.ព ជាមួយនឹង សាន់ សុន[64] និងរបាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីកំពង់ចាម ឆ្នាំ ១៩៩៧។

៣៦. សាន់ សុន បានប្រាប់ពីតួលេខជនរងគ្រោះចំនួន ១ ០០០ នាក់ដែលបានដកស្រង់នេះ។ គាត់ត្រូវបានអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ស្តាប់ចម្លើយឡើងវិញ[65]។

៣៧. របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា បានបញ្ជាក់ថា មនុស្សច្រើនរហូតដល់ ២៥ ០០០ នាក់ប្រហែលជាស្លាប់នៅគោកព្រីង[66]។ ប៉ុន្តែ តួលេខនេះ ស.ព.អ មិនបានពឹងផ្អែកឡើយ។ ទោះយ៉ាងណា ស៊ិន ឃិន ត្រូវបានអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស សាកសួរអំពីរបៀបដែលទទួលបានតួលេខនេះ[67]។

### ឆ) *ប៉ាន់ប្រមាណថា ជនជាតិចាមប្រមាណ ១០ ០០០នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួន*

៣៨. ការអះអាងនេះមានប្រភពមកពីកថាខណ្ឌ ៤៧ នៃដីកាសន្និដ្ឋានទី ៣ ដែលយោងលើរបាយការណ៍របស់ Henri Locard និងការស្តាប់ចម្លើយរបស់ ក.ស.ព ជាមួយនឹង មឿង ប៉េងហោ[68]។

៣៩. មឿង ប៉េងហោ មិនបានប៉ាន់ស្មានអំពីចំនួនជនរងគ្រោះសរុបឡើយនៅក្នុងចម្លើយដើមរបស់គាត់។ គាត់ស្លាប់ហើយ មិនអាចស្តាប់ចម្លើយសាឡើងវិញបានឡើយ[69]។

---

[64] សំណុំរឿង០០៤ ឯកសារ D1.3.11.45 *កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ សាន់ សុន* ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៨។

[65] សំណុំរឿង០០៤ ឯកសារ D107/2 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ សុន* ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១។

[66] របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីពីកំពង់ចាមឆ្នាំ ១៩៩៧ ទំព័រ ១៣។

[67] សំណុំរឿង០០៤ ឯកសារ D219/366 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន ឃិន* ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥។

[68] សំណុំរឿង០០៤ ឯកសារ D1.3.11.31 *កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយ ស៊ិន ឃិន* ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៨។

៤០. នៅក្នុងរបាយការណ៍របស់គាត់ Henri Locard ធ្វើការបញ្ជាក់ចំនួនពីរទាក់ទងនឹងតួលេខជនរងគ្រោះចំនួន ១០ ០០០ នាក់នៅវត្តអូរត្រកួន។

*"អ្នកទោសត្រូវបានគេដឹកមកតាមរទេះសេះ ឬរទេះគោ នៅពេលយប់ ប្រហែលជា ៥ រទេះ ជារៀងរាល់យប់ ដោយក្នុងមួយរទេះៗ មានអ្នកទោសពី ២-៣ រហូតដល់ ៨ នាក់។ អ្នកទោសទាំងនេះត្រូវបានគេដឹកមកពីឃុំរកាគយ ឃុំពាមជីកង និងឃុំអង្គរបាន ពោលគឺ ជនជាតិចាមជិត ១០ ០០០ នាក់មកពីឃុំទាំងនោះនៅក្នុងឆ្នាំ ១៩៧៧"* [70] ។

*"ក្នុងមួយអាទិត្យ ខ្មែរក្រហមអាចសម្លាប់អ្នកទោសពី ២០ទៅ ២០០នាក់។ ប្រសិនបើយើងយកចំនួន ៥០ ជាមធ្យម មកគុណនឹង ១៨៨ អាទិត្យ ក្នុងមួយរបបនោះ យើងនឹងឃើញចំនួនជនរងគ្រោះ ៩ ៤០០ នាក់ឬប្រហែល ១០ ០០០នាក់"* [71] ។

៤១. របាយការណ៍នេះ ក៏យោងលើចម្លើយរបស់ ម៉ៅ ហួ(Mao Huo) [72] ដែល ក.ស.ព មិនបានស្តាប់ចម្លើយឡើយ ហើយ ក.ស.ច.ស ក៏នឹងមិនស្តាប់ចម្លើយដែរ ពីព្រោះថា ផ្អែកតាមព័ត៌មានដែលមាននៅក្នុងរបាយការណ៍របស់ Henri Locard ការដឹងឮរបស់សាក្សីរូបនេះអំពីចំនួនជនរងគ្រោះនៅវត្តអូរត្រកួន គឺផ្អែកលើប្រភពមិនអាចទុកចិត្តបាន[73]។ ហេតុនេះ ខ្ញុំយល់ឃើញថា មិនចាំបាច់ស្តាប់ចម្លើយគាត់ ដើម្បីបញ្ជាក់ពីការពិតឡើយ។

*ជ) សម្រេចថា នៅក្នុងខេត្តកំពង់ចាម "ចំនួនភាគរយខ្ពស់យ៉ាងច្រើន"នៃជនជាតិភាគតិចត្រូវបានសម្លាប់*

៤២. ការអះអាងនេះមានប្រភពមកពីកថាខណ្ឌ ៤៨ នៃដីកាសន្និដ្ឋានទី ៣ ដែលយោងលើរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីកំពង់ចាម ឆ្នាំ ១៩៩៧ និងរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីកំពង់ធំ ឆ្នាំ ១៩៩៧ និង របាយការណ៍របស់មជ្ឈមណ្ឌល

---

[69]សំណុំរឿង00៤ ឯកសារ D117/69 *កំណត់ហេតុនៃកិច្ចស៊ើបសួរ* ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[70]របាយការណ៍របស់ Henri Locard ទំព័រ ១៦។

[71]របាយការណ៍របស់ Henri Locard ទំព័រ ១៧។

[72]របាយការណ៍របស់ Henri Locard ទំព័រ ១៧។

[73]របាយការណ៍របស់ Henri Locard ទំព័រ ១៦។

ឯកសារកម្ពុជាស្តីពីបាត់ដំបង ឆ្នាំ ១៩៩៧។ វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់ដើម្បីរៀបចំរបាយការណ៍ទាំងនេះត្រូវបានស៊ើបអង្កេតរួចហើយ។

៤៣. តាមសំអាងហេតុដែលបានបង្ហាញនៅកថាខណ្ឌ ១៦ ដល់ ២០ ខាងលើ ខ្ញុំមិនយល់ឃើញថាចាំបាច់ត្រូវស៊ើបអង្កេតថែមទៀតលើវិធីសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឡើយ។

*i) សេចក្តីសន្និដ្ឋាន*

៤៤. តាមសំអាងហេតុដូចបានបញ្ជាក់ខាងលើ ខ្ញុំយល់ឃើញថា ឯកសារភស្តុតាងដែលមាននៅក្នុងសំណុំរឿងនាពេលបច្ចុប្បន្ននេះ គឺមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីស្វែងយល់ពីវិធីសាស្ត្រដែល ស.ព.អ បានប្រើប្រាស់សម្រាប់ការចោទប្រកាន់ ក) ដល់ ជ) ដូចបានបង្ហាញដោយមេធាវីការពារក្តី។ មេធាវីការពារក្តី មិនបានបង្ហាញឱ្យបានច្បាស់លាស់អំពីសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតដែលអាចជួយបញ្ជាក់ពីការពិតទេ។ ដូចបានលើកឡើងខាងលើ មេធាវីការពារក្តី មានបន្ទុកត្រូវបង្ហាញអត្តសញ្ញាណសាក្សីជាក់លាក់ ឬប្រភពភស្តុតាងផ្សេងទៀត ហើយផ្តល់មូលហេតុថាតើហេតុអ្វីបានជាភស្តុតាងទាំងនោះនឹងក្លាយជាភស្តុតាងដោះបន្ទុកជាបឋម[74]។

## គ. វាយតម្លៃភាពអាចទុកចិត្តបាននៃវិធីសាស្ត្រដែលបានប្រើប្រាស់

៤៥. ការស៊ើបអង្កេតសំណុំរឿង ០០៤ កំពុងតែបន្តដំណើរការ ទោះបីជាថា ការស៊ើបអង្កេតនេះដល់ដំណាក់កាលខ្ពស់ក៏ដោយចុះ។ តាមធម្មតា ខ្ញុំធ្វើការវាយតម្លៃភាពអាចទុកចិត្តបាននៃភស្តុតាងទាំងអស់ដែលប្រមូលបាននៅក្នុងអំឡុងពេលស៊ើបអង្កេត។ មេធាវីការពារក្តី មិនបានបង្ហាញឱ្យបានច្បាស់លាស់អំពីសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតដែលអាចនាំឱ្យមានលទ្ធផលភស្តុតាងដោះបន្ទុកជាបឋមដែលជួយបញ្ជាក់ពីការពិតទេ ប៉ុន្តែបែរស្នើថា ខ្ញុំគួរតែបំពេញមុខងារមួយដែលមានជាប់រួចជាស្រេចនៅក្នុងការបំពេញតួនាទីរបស់ខ្ញុំ ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[75]។

---

[74]សំណុំរឿង០០២ ឯកសារ D100/9/2 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទីពីររបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរ* ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៣១។

[75]សំណុំរឿង០០១ ឯកសារ D99/3/42 *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច"* ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ៣៣-៣៩។

៤៦. ប៉ុន្តែ ខ្ញុំយល់ឃើញថា មេធាវីការពារក្តី នឹងចាំបាច់ត្រូវប្រើប្រាស់ធនធានមានកំណត់របស់ខ្លួន ដោយផ្តោតលើផ្នែកស៊ើបសួរដែលពាក់ព័ន្ធច្រើនបំផុត។ ហេតុនេះ ខ្ញុំផ្តល់សេចក្តីបញ្ជាក់បំភ្លឺ ដូចខាងក្រោមអំពីភស្តុតាងដែលខ្ញុំមានចេតនាពឹងផ្អែកនៅក្នុងដីកាដំណោះស្រាយ។

៤៧. ផ្ទុយពីការអះអាងរបស់មេធាវីការពារក្តី ខ្ញុំមិនយល់ស្របថា វិធីសាស្ត្ររបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា"*គឺជាមូលដ្ឋាននៃការចោទប្រកាន់មកលើ អោ អាន ឡើយ*"នៅពេលនេះ[76]។ ដោយមិនគិតថាវាអាចបែបនោះមែនឬក៏អត់នោះទេ តាមគោលបំណងនៃដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរ កិច្ចស៊ើបសួរបានបន្តដំណើរការ។ បន្ថែមពីលើនេះទៀត សំណើដើម ដំបូងដែលស្នើសុំបំពេញកិច្ចស៊ើបសួរនេះគឺបានដាក់កាលពីជាងពីរឆ្នាំមុន ហើយសេចក្តីកែប្រែ សំណើសុំបំពេញកិច្ចស៊ើបសួរនេះបានដាក់កាលពីជាងមួយឆ្នាំមុន។ មូលដ្ឋានសម្រាប់សេចក្តី សម្រេចដែលខ្ញុំនឹងធ្វើឡើងនៅក្នុងដីកាដំណោះស្រាយ ហើយក៏ជាអ្វីដែលសំខាន់សម្រាប់ពេល ឥឡូវនេះគឺភស្តុតាងទាំងអស់ដែលបានរកឃើញនៅក្នុងអំឡុងពេលស៊ើបសួរចាប់តាំងពីមាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយអាចរាប់បញ្ចូលទាំងឯកសារដែល ស.ព.អ បាន ពឹងផ្អែកសម្រាប់រៀបចំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំពោះចំណុចណាដែលកិច្ចស៊ើប សួរ រកឃើញថាមានភាពពាក់ព័ន្ធ និងអាចទុកចិត្តបាន។

៤៨. ក្រោយពីបានវាយតម្លៃភស្តុតាងទីតាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការចោទប្រកាន់មកលើ អោ អាន រួចមក ខ្ញុំយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ពីសាក្សីនានាដែលអាចផ្តល់ភស្តុតាងផ្ទាល់ បញ្ជាក់ពីទីតាំងឧក្រិដ្ឋកម្មទាំងនោះ។ ហេតុនេះ នៅពេលដែលគណនាចំនួនជនរងគ្រោះដែល អោ អាន អាចទទួលខុសត្រូវ ខ្ញុំនឹងពឹងផ្អែកជាចម្បងលើភស្តុតាងពីសាក្សីទាំងនោះ។ នៅក្នុង ដីកាដំណោះស្រាយ ខ្ញុំនឹងពឹងផ្អែកតែលើឯកសារណាដែលជាមូលដ្ឋានសម្រាប់ការប៉ាន់ស្មាន របស់ ស.ព.អ ត្រង់ចំណុចណាដែលខ្ញុំចាត់ទុកថាអាចទុកចិត្តបានតែប៉ុណ្ណោះនៅក្នុងបរិបទនៃ កិច្ចស៊ើបសួរទាំងមូល។ ពេលវេលាសម្រាប់ចេញដីកាបែបនោះ គឺធ្វើឡើងបន្ទាប់ពីភាគី ទាំងអស់បានដាក់សារណាស្តាពររបស់ខ្លួនរួចហើយ។ ជាធម្មតា ការវាយតម្លៃណាមួយ និងការ វាយតម្លៃទាំងអស់អំពីភស្តុតាងដើម្បីកំណត់ពីលក្ខណៈ និងខ្លឹមសារនៃដីកាដំណោះស្រាយ នឹង

---

[76]សំណុំរឿង00៤ ឯកសារ D188/1 *សេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២* ថ្ងៃទី 0៧ ខែ ឧសភា ឆ្នាំ ២0១៥ កថាខណ្ឌ ២៣។

ត្រូវធ្វើឡើង ដោយអនុវត្តយ៉ាងពេញលេញនូវគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនចាប់ចោទ។

៤៩. ហេតុនេះ ការស៊ើបអង្កេតថែមទៀតទាក់ទងនឹងវិធីសាស្ត្រ និងចំនួនដែល ស.ព.អ បានប៉ាន់ស្មាន មិនចាំបាច់ធ្វើឡើងឡើយ ហើយនឹងមិនជួយការពារក្តី អោ អាន ផងដែរ។

**ឃ. កាលបរិច្ឆេទ និងមូលហេតុនៃការស្លាប់**

៥០. មេធាវីការពារក្តី ត្រឹមត្រូវដែលបញ្ជាក់ថា ភស្តុតាងបញ្ជាក់ពីពេលវេលា និងមូលហេតុនៃការស្លាប់ គឺពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមួយចំនួន ដែល អោ អាន ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ គឺមនុស្សឃាត ជាការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍។

៥១. ប្រសិនបើធ្វើការស៊ើបអង្កេតកោសលវិច័យក្នុងរយៈពេលប្រហែលជា ៤០ ឆ្នាំបន្ទាប់ពីហេតុការណ៍សម្លាប់មនុស្សដែលបានចោទ ក៏នឹងមិនមានលទ្ធផលទទួលបានតម្លៃភស្តុតាងឡើយ ដោយសារពេលវេលាដែលកន្លងផុតទៅ ការខូចខាតទីតាំងប្រព្រឹត្ត និងការផ្លាស់ទីសំណល់សាកសព ដូចបានកត់សម្គាល់នៅក្នុងរបាយការណ៍អ្នកជំនាញប្រជាសាស្ត្រ[77]។ ហេតុនេះ ខ្ញុំមិនមានបំណងជីកគាស់រកសាកសពថែមទៀតឡើយ។ ប៉ុន្តែ ខ្ញុំមានបំណងកម្រិតការស៊ើបអង្កេតអំពីពេលវេលា និងមូលហេតុនៃការស្លាប់ នៅត្រឹមភស្តុតាងដែលប្រមូលបានតាមរយៈការស្តាប់ចម្លើយសាក្សីវិញ។

**ង. ការតែងតាំងអ្នកជំនាញ**

៥២. ទោះបីជារបាយការណ៍អ្នកជំនាញប្រជាសាស្ត្រ មិនផ្តោតឱ្យបានជាក់លាក់ទៅលើភូមិភាគកណ្តាល យ៉ាងណាក៏ដោយ ក៏របាយការណ៍នេះ ពិនិត្យបានគ្រប់គ្រាន់អំពីដំណើរការនីតិវិធីដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានប្រើប្រាស់ និងស្ថាប័នចាត់តាំងផ្សេងទៀត ក្នុងការកំណត់ទិន្នន័យចំនួនជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដូចដែលកំណត់ហេតុស្លាប់

---

[77] *គេពុំមានលទ្ធភាពជីកគាស់កាយឆ្អឹងបានឡើយដោយសារវាជាបញ្ហាដ៏ធំ ហើយឆ្អឹងចេះតែចាប់ផ្តើមបាត់បង់ជាបណ្តើរៗ។ សំណាកមួយនៃការជីកគាស់កាយឆ្អឹងពិតជាមានប្រយោជន៍ខ្លាំងណាស់ ប៉ុន្តែសំណាកនេះក៏នឹងពុំធ្វើឱ្យគេអាចរាប់ចំនួនជនរងគ្រោះទាំងអស់បានដែរ* របាយការណ៍អ្នកជំនាញប្រជាសាស្ត្រ ទំព័រ ១៦។

01325569



ចម្លើយ ហាក់ សុផល និង ស៊ិន ឃិន បានបង្ហាញដែរ វិធីសាស្ត្ររបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគកណ្តាល គឺដូចគ្នានឹងវិធីសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានប្រើប្រាស់នៅក្នុងរបាយការណ៍នានាដែលបានដកស្រង់នៅក្នុងដីកាសន្និដ្ឋានទី ៣។ ហេតុនេះ មិនចាំបាច់តែងតាំងអ្នកជំនាញថ្មីសម្រាប់បញ្ហាដូចគ្នានេះនៅក្នុងសំណុំរឿង ០០៤ ឡើយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៥៣. **បង្គាប់** ក្រឡាបញ្ជីរបស់ ក.ស.ច.ស ត្រូវដាក់របាយការណ៍របស់ Graig Etcheson ចូលក្នុងសំណុំរឿង។

៥៤. **ជូនដំណឹង** មេធាវីការពារក្តី ថា ខ្ញុំយល់ឃើញថា វិធីសាស្ត្រដែល ស.ព.អ បានប្រើប្រាស់ដើម្បីកំណត់ពីស្ថិតិទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់អង្គហេតុចំនួន ៨ ដែលបានលើកឡើងនៅក្នុងសំណើ គឺបានស៊ើបអង្កេតគ្រប់គ្រាន់ហើយ ដូចបានពន្យល់នៅផ្នែកតួសេចក្តីនៃដីកាសម្រេចនេះ។

៥៥. **បដិសេធ** ផ្នែកផ្សេងទៀតទាំងអស់នៃសំណើ។

ភ្នំពេញ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**